# English for Study in Australia
# កម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី

## LESSON 13– Working together
## មេរៀនទី១៣ ៖ ការធ្វើកិច្ចការសាលារួមគ្នា

**STUDY NOTES**
**ឯកសារជំនួយមេរៀន**

## តួអង្គ

Angel:
អែនជល៖ និស្សិតអន្តរជាតិ
Katie:
ខេតធី៖ និស្សិតអន្តរជាតិ
Rocky:
រ៉ុកឃី៖ និស្សិតអន្តរជាតិ
Marion:
មារៀន៖ គ្រូបង្រៀនរបស់ពួកគេ

## សាច់រឿង

រ៉ុកឃី ខេតធី និងអែនជល កំពុងនៅក្នុងថ្នាក់រៀន ដោយចាប់ផ្តើមធ្វើគម្រោងស្រាវជ្រាវជាមួយគ្នា។

## ព័ត៌មាន-អ្វីដែលអ្នកអាចធ្វើបាននៅគ្រាឥឡូវនេះ

ទោះជាលោកអ្នកមិនទាន់បានចូលរៀនវគ្គ ELICOS ក៏ដោយ ក៏លោកអ្នកគួរតែប្រឹងហាត់រៀនជំនាញរបស់លោកអ្នកដែលលោកអ្នកត្រូវការដើម្បីសរសេរតែងសេចក្តីជាភាសាអង់គ្លេសឲ្យបានល្អដែរ។ ដូច្នេះដំបូង លោកអ្នកត្រូវសិក្សាកម្មវិធីវាយពុម្ពអក្សរកុំព្យូទ័រជាមុនសិន។ លោកអ្នកគ្រាន់តែចំណាយពេលតែប៉ុន្មាននាទីប៉ុណ្ណោះក្នុងមួយថ្ងៃ ដើម្បីរៀនវាយអក្សរ ដោយមិនចាំបាច់មើលក្តារវាយអក្សរឡើយ ហើយមិនយូរឡើយលោកអ្នកនឹងអាចវាយបានលឿននៅពេលលោកអ្នកចាប់ផ្តើមវាយពុម្ពអក្សរសម្រាប់ការតែងសេចក្តីនោះ។ លោកអ្នកក៏គួរតែអានការតែងសេចក្តីជាភាសាអង់គ្លេសឲ្យបានច្រើនទៅតាមដែលអាចធ្វើទៅបាន ដើម្បីឲ្យលោកអ្នកអាចទម្លាប់ខ្លួនទៅនឹងស្ទីល ក្នុងការសរសេរ ព្រមទាំងអាចសរសេរបានប្រកបដោយគុណភាព ដូចដែលបានរំពឹងទុក។

## ភាសា-សំនួនវោហារ និងឃ្លាប្រយោគដែលមានន័យមិនធម្មតា


© RadioAustralia/AMES 2008

| | |
|---|---|
| (to) pick a topic | ជ្រើសរើសប្រធានបទ។ |
| Common practice | អ្វីដែលគេនិយមធ្វើជាធម្មតា។ |
| “worth a try” | វាជាយោបល់ដ៏ល្អ ឬមានប្រយោជន៍។ |
| (to) get booked up | មិនមានពេលវេលាសម្រាប់សកម្មភាពផ្សេងទៀត។ មិនទំនេរ។ |
| (to) get together | ជួបគ្នា។ |
| (to) brainstorm | ពិភាក្សាគំនិតដំបូងៗលើប្រធានបទណាមួយ។ |
| (to) run (something) past someone | ប្រាប់អំពីគំនិតរបស់អ្នកទៅនរណាម្នាក់អំពី *(អ្វីមួយ)* ។ |
| A hot topic | ប្រធានបទដែលបច្ចុប្បន្នមានការពេញនិយមខ្លាំង។ |


© RadioAustralia/AMES 2008

# EXERCISES
# លំហាត់

## ១. វាក្យសព្ទសំខាន់ៗ

សូមផែកអត្ថន័យ និងការបញ្ចេញសំឡេងនៃពាក្យទាំងអស់នេះនៅក្នុងវចនានុក្រមរបស់លោកអ្នក ៖

| | | |
|---|---|---|
| assessment | cause | (to) concern |
| (to) compare | (to) conduct | confidential |
| (to) discover | focus | (to) pass |
| plagiarism | purpose | questionnaire |
| relevant | research | scribe |
| source | strategy | topic |

## ២. ការហាត់រៀនភាសា លំហាត់គំរូ ការធ្វើតេស្តស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេស

ដើម្បីអាចចូលរៀនក្នុងវគ្គសិក្សាណាមួយនោះ លោកអ្នកត្រូវធ្វើតេស្តដើម្បីស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេស ជាមុនសិន។ សូមកត់ចំណាំថា ការណែនាំក្នុងការធ្វើតេស្ត ជាទូទៅ សរសេរជាភាសាអង់គ្លេស (ដូចខាងក្រោម)។

Choose the word that best completes each sentence.
ចូរជ្រើសយកពាក្យដែលសមស្របបំផុតសម្រាប់ដាក់ទៅក្នុងចន្លោះនៃអត្ថបទក្នុងប្រអប់ខាងក្រោម។
សូមគូសខ្វែងក្នុងប្រអប់មួយសម្រាប់លេខនីមួយៗ។ ឧទាហរណ៍ ☒

| | | | | |
|---|---|---|---|---|
| 1. | ☐ on | ☐ to | ☐of | ☐ in |
| 2 | ☐ that | ☐ which | ☐ for | ☐ by |
| 3. | ☐ those | ☐ these | ☐ which | ☐ that |
| 4 | ☐ likeable | ☐ like | ☐ likely | ☐ liking |
| 5 | ☐ as | ☐ good | ☐ much | ☐ most |

## ៣. ឧបសគ្គក្នុងការប្រើប្រាស់ភាសា

ABC Radio Australia


© RadioAustralia/AMES 2008

**សូរសំឡេង <u>/ θ / and / ð /</u>** ៖ សូមហាត់និយាយពាក្យដ៏ពិបាកទាំងនេះដោយបញ្ចេញសំឡេងឲ្យបានឮៗ ៖

**"The theme of this essay is health"**

## <u>៤. អាសយដ្ឋានអ៊ីនធើរណិតដែលមានប្រយោជន៍</u>

| | |
|---|---|
| ព័ត៌មាន ៖ <br> កម្មវិធីរៀនវាយពុម្ពអក្សរតាមអ៊ីនធើរណិតដោយឥតគិតថ្លៃ។ | http://www.typeonline.co.uk/ |
| ការណែនាំសម្រាប់ការធ្វើបទបង្ហាញលើការងារសិក្សា។ | http://www.ballarat.edu.au/aasp/student/learning_support/generalguide/ |
| ការសរសេរតែងសេចក្តីតាមបែបប្រៀបធៀប។ | http://www.wikihow.com/Write-a-Comparative-Essay |

ចម្លើយលំហាត់ទី 2: 1) of 2) that 3) which 4) likely 5) as

ABC Radio Australia


© RadioAustralia/AMES 2008